ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៣៥០ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជា
## លេខ ៩ ស្តីពីចំណូលពីប្រតិបត្តិការដោះដូរ និង លេខ ២៣ ស្តីពីចំណូលពីប្រតិបត្តិការមិនដោះដូរ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញប្រកាសលេខ ០០៧ អ.ស.ហ.ប្រក. ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទរបស់និយ័តករគណនេយ្យនិងសវនកម្ម
- យោងតាមសំណើរបស់និយ័តករគណនេយ្យនិងសវនកម្ម



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

## សម្រេច

**ប្រការ១.-**

ត្រូវបានដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជា ចំនួន ២ គឺ៖

១. ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ៩ ស្តីពីចំណូលពីប្រតិបត្តិការដោះដូរ និង

២. ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ២៣ ស្តីពីចំណូលពីប្រតិបត្តិការមិនដោះដូរ។

ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ៩ ស្តីពីចំណូលពីប្រតិបត្តិការដោះដូរ និងស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ២៣ ស្តីពីចំណូលពីប្រតិបត្តិការមិនដោះដូរ ត្រូវបានរៀបចំឡើងដោយផ្អែកលើមូលដ្ឋាន "ស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈមូលដ្ឋានបង្គរ"។

ស្តង់ដាគណនេយ្យសាធារណៈកម្ពុជាដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការ១ នៃប្រកាសនេះ ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ២.-**

និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អាចចេញគោលការណ៍ណែនាំស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ៩ ស្តីពីចំណូលពីប្រតិបត្តិការដោះដូរ និង លេខ ២៣ ស្តីពីចំណូលពីប្រតិបត្តិការមិនដោះដូរ និងត្រូវផ្តល់ការគាំទ្រផ្នែកបច្ចេកទេសស្តង់ដាគណនេយ្យដល់គណនេយ្យករសាធារណៈ តាមការចាំបាច់។

និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ត្រូវធ្វើបច្ចុប្បន្នភាពស្តង់ដាគណនេយ្យសាធារណៈកម្ពុជា និងចេញផ្សាយសម្រាប់ការអនុវត្ត ស្របតាមបរិបទរបស់អន្តរជាតិ ក្នុងករណីចាំបាច់។

**ប្រការ៣.-**

អគ្គនាយកដ្ឋានរតនាគារជាតិ ក្នុងនាមជាគណនេយ្យករសាធារណៈ ត្រូវកត់ត្រា និងប្រមូលផ្តុំនូវប្រតិបត្តិការចំណូល និងដាក់បង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ព្រមទាំងលាតត្រដាងព័ត៌មានអំពីចំណូល និងគណនីត្រូវទទួលពាក់ព័ន្ធ ឱ្យស្របតាមស្តង់ដាគណនេយ្យសាធារណៈកម្ពុជាដូចមានចែងក្នុងប្រការ១ នៃប្រកាសនេះ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ តទៅ។

ចាប់ពីថ្ងៃចេញប្រកាសនេះ អគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវរៀបចំហេដ្ឋារចនាសម្ព័ន្ធគណនេយ្យសាធារណៈ ឱ្យបានរួចរាល់ និងត្រូវចាប់ផ្តើមអនុវត្តជាបណ្តើរៗ សម្រាប់ការអនុវត្តគណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល ២០២៥-២០២៧ ជាផ្លូវការ។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការក្រសួង អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយក

ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**<u>កន្លែងទទួល៖</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ឯកឧត្តម លោកជំទាវជាអនុប្រធាន និងសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

  “ដើម្បីជូនជ្រាប”
- ដូចប្រការ ៥

  “ដើម្បីអនុវត្ត”
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ៩ ស្តីពី ចំណូលពីប្រតិបត្តិការដោះដូរ

## ការទទួលស្គាល់

ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា (CPSAS) លេខ ៩ ត្រូវបានរៀបចំដោយផ្អែកលើស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ (IPSAS) 9, ចំណូលពីប្រតិបត្តិការដោះដូរ, ចេញពីសៀវភៅសេចក្តីប្រកាសគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ របស់ ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ (IPSASB) ដែលបានចេញផ្សាយដោយ សហព័ន្ធគណនេយ្យករអន្តរជាតិ (IFAC) នៅក្នុងខែកក្កដា ឆ្នាំ២០២០ ហើយត្រូវបានប្រើប្រាស់ដោយមានការអនុញ្ញាតពីសហព័ន្ធគណនេយ្យករអន្តរជាតិ។

សៀវភៅសេចក្តីប្រកាសគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ ©2020 ដោយសហព័ន្ធគណនេយ្យករអន្តរជាតិ (IFAC)។ សូមរក្សាសិទ្ធិគ្រប់យ៉ាង។

ចេញផ្សាយដោយ÷

និយ័តករគណនេយ្យនិងសវនកម្ម

ផ្លូវលេខ ៩២, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ

លេខទូរស័ព្ទ÷ +(855) 23 882 111

អ៊ីម៉ែល÷ info@acar.gov.kh

គេហទំព័រ÷ www.acar.gov.kh

# ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ៩ ស្តីពី ចំណូលពីប្រតិបត្តិការដោះដូរ

## មាតិកា

កថាខណ្ឌ

គោលបំណង
វិសាលភាព........................................ ១-១០
និយមន័យ........................................ ១១-១៣
    ចំណូល........................................ ១២-១៣
ការវាស់វែងចំណូល........................................ ១៤-១៧
ការកំណត់អត្តសញ្ញាណប្រតិបត្តិការ........................................ ១៨
ការផ្តល់សេវា........................................ ១៩-២៧
ការលក់ទំនិញ ........................................ ២៨-៣២
ការប្រាក់, សួយសារ, និងភាគលាភ........................................ ៣៣-៣៨
ការលាតត្រដាង........................................ ៣៩-៤០

## គោលបំណង

ស្តង់ដានេះមានគោលបំណងកំណត់និយមន័យប្រាក់ចំណូល (Income) ជា "ការកើនឡើងនៃអត្ថប្រយោជន៍សេដ្ឋកិច្ចក្នុងអំឡុងការិយបរិច្ឆេទគណនេយ្យ ក្នុងទម្រង់ជាលំហូរចូល ឬ ការកើនឡើងទ្រព្យសកម្ម ឬ ការថយចុះបំណុល ដែលជាលទ្ធផលនាំឱ្យមានការកើនឡើងមូលធន ជាជាងការកើនឡើងដែលពាក់ព័ន្ធនឹងការចូលរួមវិភាគទានពីម្ចាស់មូលធន"។ និយ័តករគណនេយ្យនិងសវនកម្ម កំណត់ថា ប្រាក់ចំណូល រាប់បញ្ចូលទាំងចំណូល (Revenue) និងផលចំណេញ (Gains)។ ស្តង់ដានេះប្រើប្រាស់ពាក្យ "ចំណូល" ដែលរាប់បញ្ចូលទាំងចំណូល (Revenues) និងផលចំណេញ (Gains) ជំនួសឱ្យពាក្យ "ប្រាក់ចំណូល"។ ធាតុជាក់លាក់មួយចំនួនដែលត្រូវទទួលស្គាល់ជាចំណូល ត្រូវបានបង្ហាញក្នុងស្តង់ដាផ្សេងទៀត និងត្រូវបានដកចេញពីវិសាលភាពនៃស្តង់ដានេះ។ ឧទាហរណ៍ ផលចំណេញដែលបានមកពីការលក់ទ្រព្យ រោងចក្រ និងបរិក្ខារ ត្រូវបានបង្ហាញយ៉ាងជាក់លាក់នៅក្នុងស្តង់ដាស្តីពី ទ្រព្យ រោងចក្រ និងបរិក្ខារ ហើយមិនមានចែងនៅក្នុងស្តង់ដានេះទេ។

គោលបំណងនៃស្តង់ដានេះ គឺដើម្បីកំណត់អំពីប្រព្រឹត្តិកម្មគណនេយ្យនៃចំណូលដែលកើតឡើងពីប្រតិបត្តិការ និងព្រឹត្តិការណ៍ដោះដូរ។

បញ្ហាចម្បងក្នុងការធ្វើគណនេយ្យកម្មសម្រាប់ចំណូល គឺការកំណត់ថាតើចំណូលត្រូវទទួលស្គាល់នៅពេលណា។ ចំណូលត្រូវបានទទួលស្គាល់ នៅពេលដែលវាអាចនឹងកើតមានឡើងដែល (ក) អត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវានាពេលអនាគត នឹងហូរចូលស្ថាប័ន ហើយ (ខ) អត្ថប្រយោជន៍ទាំងនេះ អាចត្រូវបានវាស់វែងដោយជឿទុកចិត្ត។ ស្តង់ដានេះកំណត់អំពីស្ថានភាពដែលលក្ខណៈវិនិច្ឆ័យទាំងនេះនឹងត្រូវបានបំពេញ ហើយដូចនេះ ចំណូលនឹងត្រូវបានទទួលស្គាល់។ ស្តង់ដានេះក៏ផ្តល់នូវការណែនាំអំពីការអនុវត្តលក្ខណៈវិនិច្ឆ័យទាំងនេះផងដែរ។

## វិសាលភាព

១. **ស្ថាប័នដែលរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យបង្គរ ត្រូវអនុវត្តស្តង់ដានេះក្នុងការធ្វើគណនេយ្យកម្មសម្រាប់ចំណូលដែលកើតឡើងពីប្រតិបត្តិការ និងព្រឹត្តិការណ៍ដោះដូរ ដូចខាងក្រោម÷**

(ក) **ការផ្តល់សេវា**

(ខ) **ការលក់ទំនិញ និង**

(គ) **ការប្រើប្រាស់ទ្រព្យសកម្មដោយស្ថាប័នដទៃ ដែលផ្តល់ផលជាការប្រាក់ សួយសារ និងភាគលាភ ឬ ការបែងចែកប្រហាក់ប្រហែល ។**

២. [លុបចេញ]

៣. [លុបចេញ]

៤. ស្តង់ដានេះមិនគ្របដណ្តប់លើចំណូលដែលកើតឡើងពីប្រតិបត្តិការមិនដោះដូរនោះទេ។

៥. ស្ថាប័នសាធារណៈអាចទទួលបានចំណូលពីប្រតិបត្តិការដោះដូរ ឬ ប្រតិបត្តិការមិនដោះដូរ។ ប្រតិបត្តិការដោះដូរ គឺជាប្រតិបត្តិការមួយដែលស្ថាប័នទទួលបានទ្រព្យសកម្ម ឬ សេវា ឬ ស្ថាប័នមានបំណុលផុតរលត់ ហើយផ្តល់តម្លៃប្រហាក់ប្រហែលដោយផ្ទាល់ (ជាចម្បងក្នុងទម្រង់ជាទំនិញ សេវា ឬ ការប្រើប្រាស់ទ្រព្យសកម្ម) ទៅឱ្យភាគីផ្សេងទៀត ជាការដោះដូរ។ ឧទាហរណ៍នៃប្រតិបត្តិការដោះដូរ រួមមាន÷

(ក) ការទិញ ឬ ការលក់ទំនិញ ឬ សេវា ឬ

(ខ) ការជួលទ្រព្យ រោងចក្រ និងបរិក្ខារ តាមអត្រាទីផ្សារ។

៦. ក្នុងការញែកគ្នារវាងចំណូលពីប្រតិបត្តិការដោះដូរ និងចំណូលពីប្រតិបត្តិការមិនដោះដូរ ស្ថាប័នគួរពិចារណាលើខ្លឹមសារ ជាជាងទម្រង់នៃប្រតិបត្តិការ។ ប្រតិបត្តិការមិនដោះដូរ រួមមាន ចំណូលពីការប្រើប្រាស់អំណាចអធិបតេយ្យ (ឧទាហរណ៍ ពន្ធផ្ទាល់ និងពន្ធប្រយោល, អាករ និងការផាកពិន័យ), អំណោយ និងការបរិច្ចាគ។

៧. ការផ្តល់សេវា ជាទូទៅ ជាប់ពាក់ព័ន្ធនឹងការអនុវត្តការងាររបស់ស្ថាប័នទៅលើការងារដែលបានព្រមព្រៀងនៅក្នុងអំឡុងការិយបរិច្ឆេទដែលបានព្រមព្រៀងណាមួយ។ សេវាអាចត្រូវបានផ្តល់នៅក្នុងការិយបរិច្ឆេទមួយ ឬ ច្រើនជាងមួយការិយបរិច្ឆេទ។ ឧទាហរណ៍ សេវាដែលបានផ្តល់ដោយស្ថាប័នសាធារណៈ ដែលចំណូលជាទូទៅត្រូវបានទទួលជាការដោះដូរ អាចរួមមាន ការផ្តល់លំនៅដ្ឋាន, ការគ្រប់គ្រងប្រព័ន្ធបរិក្ខារទឹក, ការគ្រប់គ្រងផ្លូវបង់ប្រាក់ និងការគ្រប់គ្រងការទូទាត់ការផ្ទេរ។ កិច្ចព្រមព្រៀងមួយចំនួនសម្រាប់ការផ្តល់សេវា គឺពាក់ព័ន្ធដោយផ្ទាល់ទៅនឹងកិច្ចសន្យាសាងសង់ ឧទាហរណ៍ កិច្ចព្រមព្រៀងសម្រាប់សេវារបស់អ្នកគ្រប់គ្រងគម្រោង និងស្ថាបត្យករ។ ចំណូលដែលកើតឡើងពីកិច្ចព្រមព្រៀងទាំងនេះ មិនបានចែងនៅក្នុងស្តង់ដានេះទេ ប៉ុន្តែត្រូវបានចែងដោយអនុលោមតាមលក្ខខណ្ឌចាំបាច់សម្រាប់កិច្ចសន្យាសាងសង់ ដូចបានកំណត់នៅក្នុងស្តង់ដា CPSAS 11 កិច្ចសន្យាសាងសង់។

៨. ទំនិញ រួមមាន (ក) ទំនិញដែលបានផលិតដោយស្ថាប័នក្នុងគោលបំណងសម្រាប់លក់ ដូចជា ការបោះពុម្ពផ្សាយ និង (ខ) ទំនិញដែលបានទិញសម្រាប់លក់បន្ត ដូចជា ទំនិញ ឬ ដី និងទ្រព្យផ្សេងទៀតដែលត្រូវបានរក្សាទុកសម្រាប់លក់បន្ត។

៩. ការប្រើប្រាស់ទ្រព្យសកម្មដោយស្ថាប័នដទៃ បង្កើតឱ្យមានចំណូល ក្នុងទម្រង់ជា÷

(ក) ការប្រាក់ – បន្ទុកក្នុងការប្រើប្រាស់សាច់ប្រាក់ ឬ សាច់ប្រាក់សមមូល ឬ ចំនួនទឹកប្រាក់ដែលស្ថាប័នត្រូវទទួល

(ខ) សួយសារ – បន្ទុកក្នុងការប្រើប្រាស់ទ្រព្យសកម្មរយៈពេលវែងរបស់ស្ថាប័ន ឧទាហរណ៍ ប្រកាសនីយបត្រ (ប៉ាតង់), សញ្ញាពាណិជ្ជកម្ម, សិទ្ធិអ្នកនិពន្ធ និងកម្មវិធីកុំព្យូទ័រ និង

(គ) ភាគលាភ ឬ ការបែងចែកប្រហាក់ប្រហែល – ការបែងចែកអតិរេកទៅឱ្យអ្នកកាន់កាប់ការវិនិយោគមូលធន ដោយសមាមាត្រតាមការកាន់កាប់ថ្នាក់ជាក់លាក់ណាមួយនៃដើមទុន។

១០. ស្តង់ដានេះ មិនអនុវត្តចំពោះចំណូលដែលកើតឡើងពី÷

(ក) កិច្ចព្រមព្រៀងភតិសន្យា (សូមមើលស្តង់ដា CPSAS 13 ភតិសន្យា)

(ខ) ភាគលាភ ឬ ការបែងចែកប្រហាក់ប្រហែល ដែលកើតឡើងពីការវិនិយោគនានាដែលត្រូវបានធ្វើគណនេយ្យកម្មតាមវិធីសាស្ត្រមូលធន (សូមមើលស្តង់ដា CPSAS 36 ការវិនិយោគនៅក្នុងញាតិ-សម្ព័ន្ធ និងក្រុមហ៊ុនរួមទុន)។

(គ) ផលចំណេញពីការលក់ទ្រព្យ រោងចក្រ និងបរិក្ខារ (ដូចមានចែងក្នុងស្តង់ដា CPSAS 17 ទ្រព្យ រោងចក្រ និងបរិក្ខារ)

(ឃ) កិច្ចសន្យាធានារ៉ាប់រងនៅក្នុងវិសាលភាពនៃស្តង់ដាគណនេយ្យជាតិ ឬ អន្តរជាតិពាក់ព័ន្ធ ដែលចែងអំពីកិច្ចសន្យាធានារ៉ាប់រង

(ង) បម្រែបម្រួលតម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ឬ ការលក់ចេញ (សូមមើលស្តង់ដា CPSAS 41 ឧបករណ៍ហិរញ្ញវត្ថុ)

(ច) បម្រែបម្រួលតម្លៃទ្រព្យសកម្មរយៈពេលខ្លីផ្សេងទៀត

(ឆ) ការទទួលស្គាល់លើកដំបូង និងពីបម្រែបម្រួលតម្លៃសមស្របនៃទ្រព្យសកម្មជីវសាស្ត្រដែលពាក់ព័ន្ធនឹងសកម្មភាពកសិកម្ម (សូមមើលស្តង់ដា CPSAS 27 កសិកម្ម)

(ជ) ការទទួលស្គាល់លើកដំបូងនៃផលិតផលកសិកម្ម (សូមមើលស្តង់ដា CPSAS 27 កសិកម្ម) និង

(ឈ) ការទាញយករ៉ែ។

## និយមន័យ

**១១. វាក្យស័ព្ទដែលបានប្រើក្នុងស្តង់ដានេះ ត្រូវបានកំណត់និយមន័យ ដូចខាងក្រោម÷**

**<u>ប្រតិបត្តិការដោះដូរ</u> គឺជាប្រតិបត្តិការដែលស្ថាប័នទទួលបានទ្រព្យសកម្ម ឬ សេវា ឬ ស្ថាប័នមានបំណុលផុតរលត់ ហើយផ្តល់តម្លៃប្រហាក់ប្រហែលដោយផ្ទាល់ (ជាចម្បងក្នុងទម្រង់ជាសាច់ប្រាក់ ទំនិញ សេវា ឬ ការប្រើ-ប្រាស់ទ្រព្យសកម្ម) ទៅឱ្យស្ថាប័នដទៃ ជាការដោះដូរ។**

**<u>តម្លៃសមស្រប</u> គឺជាចំនួនទឹកប្រាក់ដែលទ្រព្យសកម្មអាចត្រូវបានដោះដូរ ឬ បំណុលត្រូវបានទូទាត់សង រវាងភាគីស្ម័គ្រចិត្តដែលមានចំណេះដឹងនៅក្នុងប្រតិបត្តិការបើកចំហ។**

**<u>ប្រតិបត្តិការមិនដោះដូរ</u> គឺជាប្រតិបត្តិការដែលមិនមែនជាប្រតិបត្តិការដោះដូរ។ ក្នុងប្រតិបត្តិការមិនដោះដូរ, ស្ថាប័នអាចទទួលបានតម្លៃពីស្ថាប័នដទៃ ដោយមិនបានផ្តល់តម្លៃប្រហាក់ប្រហែលដោយផ្ទាល់ណាមួយជាការដោះដូរ ឬ ផ្តល់តម្លៃទៅឱ្យស្ថាប័នដទៃ ដោយមិនទទួលបានតម្លៃប្រហាក់ប្រហែលដោយផ្ទាល់ណាមួយជាការដោះដូរ។**

**វាក្យស័ព្ទដែលបានកំណត់និយមន័យក្នុងស្តង់ដា CPSAS ផ្សេងទៀត ត្រូវបានប្រើក្នុងស្តង់ដានេះ ដោយមានអត្ថន័យដូចគ្នានឹងស្តង់ដាទាំងនោះដែរ ហើយត្រូវបានកំណត់ឡើងវិញនៅក្នុង *សន្ទានុក្រមនៃវាក្យស័ព្ទដែលបានកំណត់និយមន័យ* ដែលត្រូវបានបោះពុម្ពផ្សាយដាច់ដោយឡែក។**

## ចំណូល

១២. ចំណូល រួមបញ្ចូលតែលំហូរចូលដុលនៃអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវាដែលបានទទួលនិងត្រូវទទួល ដោយស្ថាប័នផ្ទាល់។ ចំនួនទឹកប្រាក់ដែលប្រមូលបានក្នុងនាមជាភ្នាក់ងាររបស់រាជរដ្ឋាភិបាល ឬ ស្ថាប័នរាជរដ្ឋាភិបាលផ្សេងទៀត ឬ ក្នុងនាមជាភាគីទីបីផ្សេងទៀត ឧទាហរណ៍ ការប្រមូលការទូទាត់ថ្លៃទូរស័ព្ទ និងថ្លៃភ្លើងដោយការិយាល័យប្រៃសណីយ៍ ជំនួសឱ្យស្ថាប័នដែលផ្តល់សេវាទាំងនោះ មិនមែនជាអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវាដែលហូរចូលស្ថាប័ន និងមិនបង្កើតឱ្យមានការកើនឡើងទ្រព្យសកម្ម ឬ ការថយចុះបំណុលនោះទេ។ ដូចនេះ ចំនួនទឹកប្រាក់ដែលប្រមូលបាននោះ មិនត្រូវរួមបញ្ចូលជាចំណូលឡើយ។ ដូចគ្នានេះដែរ នៅក្នុងទំនាក់ទំនងរបស់ភ្នាក់ងារ លំហូរចូលដុលនៃអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវា រួមបញ្ចូលនូវចំនួនទឹកប្រាក់ដែលត្រូវបានប្រមូលជំនួសឱ្យម្ចាស់ដើម ដែលមិនបង្កើតឱ្យមានការកើនឡើងទ្រព្យសកម្ម/មូលធនសុទ្ធសម្រាប់ស្ថាប័ន។ ទឹកប្រាក់ដែលត្រូវបានប្រមូលជំនួសឱ្យម្ចាស់ដើម មិនមែនជាចំណូលនោះទេ។ ជំនួសមកវិញ ចំណូលគឺជាចំនួនទឹកប្រាក់នៃកម្រៃជើងសារណាមួយដែលបានទទួល ឬ ត្រូវទទួល សម្រាប់ការប្រមូល ឬ ការកាន់កាប់លំហូរដុលនៃអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវាទាំងនោះ។

១៣. លំហូរចូលពីហិរញ្ញប្បទាន ជាពិសេសប្រាក់កម្ចី មិនបំពេញតាមនិយមន័យចំណូលឡើយ ពីព្រោះលំហូរចូលទាំងនោះ (ក) នាំឱ្យមានបម្រែបម្រួលស្មើគ្នាទាំងទ្រព្យសកម្ម និងបំណុល និង (ខ) ពុំមានឥទ្ធិពលលើទ្រព្យ-សកម្ម/មូលធនសុទ្ធ។ លំហូរចូលពីហិរញ្ញប្បទានត្រូវបានកត់ត្រាចូលទៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដោយផ្ទាល់ និងត្រូវបានបញ្ចូលទៅក្នុងសមតុល្យនៃទ្រព្យសកម្ម និងបំណុល។

## ការវាស់វែងចំណូល

**១៤. ចំណូល ត្រូវបានវាស់វែងតាមតម្លៃសមស្របនៃតម្លៃតបស្នងដែលបានទទួល ឬ ត្រូវទទួល។**

១៥. ចំនួនទឹកប្រាក់នៃចំណូលដែលកើតឡើងលើប្រតិបត្តិការមួយ ជាទូទៅ ត្រូវបានកំណត់ដោយកិច្ចព្រមព្រៀងរវាងស្ថាប័ន និងអ្នកទិញ ឬ អ្នកប្រើប្រាស់ទ្រព្យសកម្ម ឬ សេវា។ ចំណូលត្រូវបានវាស់វែងតាមតម្លៃសមស្របនៃតម្លៃតបស្នងដែលបានទទួល ឬ ត្រូវទទួល ដោយត្រូវពិចារណាលើចំនួនទឹកប្រាក់នៃអប្បហារពាណិជ្ជកម្ម និងទំហំបង្វិលសងមកវិញ (volume rebates) ណាមួយដែលបានអនុញ្ញាតដោយស្ថាប័ន។

១៦. ក្នុងករណីភាគច្រើន, តម្លៃតបស្នង គឺស្ថិតក្នុងទម្រង់ជាសាច់ប្រាក់ ឬ សាច់ប្រាក់សមមូល ហើយចំនួនទឹកប្រាក់នៃចំណូល គឺជាចំនួនសាច់ប្រាក់ ឬ សាច់ប្រាក់សមមូលដែលបានទទួល ឬ ត្រូវទទួល។ ប៉ុន្តែ នៅពេលលំហូរ-ចូលនៃសាច់ប្រាក់ ឬ សាច់ប្រាក់សមមូល ត្រូវបានពន្យារ, តម្លៃសមស្របនៃតម្លៃតបស្នងអាចតិចជាងចំនួនសាច់ប្រាក់ជាក់ស្តែងដែលបានទទួល ឬ ត្រូវទទួល។ ឧទាហរណ៍ ស្ថាប័នអាចផ្តល់ឥណទានគ្មានការប្រាក់ ទៅឱ្យអ្នកទិញ ឬ ទទួលយកបណ្ណត្រូវទទួលប្រាក់ ដែលមានអត្រាការប្រាក់ទាបជាងទីផ្សារ ពីអ្នកទិញ ជាតម្លៃតប-ស្នងសម្រាប់ការលក់ទំនិញ។ នៅពេលដែលកិច្ចព្រមព្រៀងបង្កើតឱ្យមានជាប្រតិបត្តិការផ្តល់ហិរញ្ញប្បទាន, តម្លៃសមស្របនៃតម្លៃតបស្នងត្រូវបានកំណត់ដោយធ្វើអប្បហារទៅលើរាល់ចំណូលនាពេលអនាគតទាំងអស់

ដោយប្រើប្រាស់អត្រាការប្រាក់ដែលបានកំណត់ (imputed rate of interest)។ អត្រាការប្រាក់ដែលបានកំណត់ គឺជាអត្រាការប្រាក់ដែលអាចកំណត់បានច្បាស់លាស់អំពី÷

(ក) អត្រាដែលត្រូវអនុវត្ត (prevailing rate) សម្រាប់ឧបករណ៍ប្រហាក់ប្រហែលរបស់អ្នកបោះផ្សាយដែលមានការវាយតម្លៃឥណទានប្រហាក់ប្រហែល ឬ

(ខ) អត្រាការប្រាក់ដែលធ្វើអប្បហារលើតម្លៃជាក់ស្តែងនៃឧបករណ៍ ទៅជាតម្លៃលក់ជាសាច់ប្រាក់បច្ចុប្បន្ននៃទំនិញ ឬ សេវា។

ភាពខុសគ្នារវាងតម្លៃសមស្រប និងតម្លៃជាក់ស្តែងនៃតម្លៃតបស្នង ត្រូវបានទទួលស្គាល់ជាចំណូលពីការប្រាក់ដោយអនុលោមតាមកថាខណ្ឌ ៣៣ និង កថាខណ្ឌ ៣៤។

១៧. នៅពេលទំនិញ ឬ សេវា ត្រូវបានដោះដូរ ឬ ត្រូវបានប្តូរយកទំនិញ ឬ សេវាដែលមានចរិតលក្ខណៈនិងតម្លៃប្រហាក់ប្រហែល, ការដោះដូរមិនត្រូវបានចាត់ទុកជាប្រតិបត្តិការដែលបង្កើតឱ្យមានចំណូលនោះទេ។ ករណីដោះដូរនេះ ភាគច្រើនកើតឡើងចំពោះទំនិញដូចជា ប្រេង ឬ ទឹកដោះគោ ដែលអ្នកផ្គត់ផ្គង់ដោះដូរ ឬ ប្តូរសន្និធិគ្នានៅទីតាំងផ្សេងៗគ្នាដើម្បីបំពេញតម្រូវការឱ្យបានទាន់ពេលវេលានៅទីតាំងជាក់លាក់មួយ។ នៅពេលទំនិញត្រូវបានលក់ ឬ សេវាត្រូវបានផ្តល់ ដើម្បីដោះដូរជាមួយនឹងទំនិញ ឬ សេវាដែលមិនមានលក្ខណៈប្រហាក់ប្រហែលគ្នា, ការដោះដូរនោះត្រូវបានចាត់ទុកជាប្រតិបត្តិការដែលបង្កើតឱ្យមានចំណូល។ ចំណូលត្រូវបានវាស់វែងតាមតម្លៃសមស្របនៃទំនិញ ឬ សេវាដែលបានទទួល ដោយត្រូវបានកែតម្រូវដោយចំនួនសាច់ប្រាក់ ឬ សាច់ប្រាក់សមមូលណាមួយដែលបានផ្ទេរ។ នៅពេលតម្លៃសមស្របនៃទំនិញ ឬ សេវាដែលបានទទួល មិនអាចត្រូវបានវាស់វែងដោយជឿទុកចិត្ត, ចំណូលត្រូវបានវាស់វែងតាមតម្លៃសមស្របនៃទំនិញ ឬ សេវាដែលបានបោះបង់ ដោយត្រូវបានកែតម្រូវដោយចំនួនសាច់ប្រាក់ ឬ សាច់ប្រាក់សមមូលណាមួយដែលបានផ្ទេរ។

## ការកំណត់អត្តសញ្ញាណប្រតិបត្តិការ

១៨. ជាទូទៅ លក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់នៅក្នុងស្តង់ដានេះ ត្រូវបានអនុវត្តដាច់ដោយឡែកពីគ្នាចំពោះប្រតិបត្តិការនីមួយៗ។ ទោះបីជាយ៉ាងនេះក្តី ក្នុងស្ថានភាពជាក់លាក់ ស្ថាប័នចាំបាច់អនុវត្តលក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់ចំពោះសមាសធាតុដែលអាចកំណត់អត្តសញ្ញាណបានដាច់ដោយឡែកពីគ្នានៃប្រតិបត្តិការមួយដើម្បីឆ្លុះបញ្ចាំងពីភាពជាក់ស្តែងនៃប្រតិបត្តិការ។ ឧទាហរណ៍ នៅពេលតម្លៃផលិតផលមួយរួមបញ្ចូលនូវចំនួនទឹកប្រាក់ដែលអាចកំណត់អត្តសញ្ញាណបានសម្រាប់ការផ្តល់សេវាក្រោយការលក់ទំនិញ ចំនួនទឹកប្រាក់នោះត្រូវបានពន្យារ និងត្រូវបានទទួលស្គាល់ជាចំណូលសម្រាប់ការិយបរិច្ឆេទដែលសេវាត្រូវបានបំពេញ។ ផ្ទុយទៅវិញ លក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់ ត្រូវបានអនុវត្តចំពោះប្រតិបត្តិការពីរ ឬ ច្រើនជាមួយគ្នា នៅពេលដែលប្រតិបត្តិការទាំងនោះ ត្រូវបានតភ្ជាប់ជាមួយគ្នាតាមរបៀបដែលគេមិនអាចយល់ដឹងបានពីផលប៉ះពាល់ដោយមិនមានអំណះអំណាងទៅលើបណ្តុំប្រតិបត្តិការទាំងមូល។ ឧទាហរណ៍ ស្ថាប័នមួយអាចលក់ទំនិញ និង

ចុះកិច្ចព្រមព្រៀងដាច់ដោយឡែកក្នុងពេលតែមួយ ដើម្បីទិញទំនិញនោះត្រលប់មកវិញនាកាលបរិច្ឆេទក្រោយដែលបដិសេធឥទ្ធិពលសំខាន់នៃប្រតិបត្តិការ; ក្នុងករណីនេះ ប្រតិបត្តិការទាំងពីរត្រូវដោះស្រាយជាមួយគ្នា។

## ការផ្តល់សេវា

**១៩. នៅពេលដែលលទ្ធផលនៃប្រតិបត្តិការមួយដែលពាក់ព័ន្ធនឹងការផ្តល់សេវា អាចត្រូវបានប៉ាន់ស្មានដោយជឿទុកចិត្ត ចំណូលដែលជាប់ពាក់ព័ន្ធនឹងប្រតិបត្តិការនោះ ត្រូវទទួលស្គាល់ដោយយោងទៅលើដំណាក់កាលនៃការបញ្ចប់ប្រតិបត្តិការ នាកាលបរិច្ឆេទរាយការណ៍។ លទ្ធផលនៃប្រតិបត្តិការមួយ អាចត្រូវបានប៉ាន់ស្មានដោយជឿទុកចិត្ត នៅពេលដែលលក្ខខណ្ឌទាំងអស់ដូចខាងក្រោម ត្រូវបានបំពេញ÷**

**(ក) ចំនួនទឹកប្រាក់នៃចំណូល អាចត្រូវបានវាស់វែងដោយជឿទុកចិត្ត**

**(ខ) វាអាចនឹងកើតមានឡើងដែលអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវាដែលជាប់ពាក់ព័ន្ធនឹងប្រតិបត្តិការ នឹងហូរចូលស្ថាប័ន**

**(គ) ដំណាក់កាលនៃការបញ្ចប់ប្រតិបត្តិការនាកាលបរិច្ឆេទរាយការណ៍ អាចត្រូវបានវាស់វែងដោយជឿទុកចិត្ត និង**

**(ឃ) ចំណាយដែលបានកើតឡើងសម្រាប់ប្រតិបត្តិការ និងចំណាយដើម្បីបញ្ចប់ប្រតិបត្តិការ អាចត្រូវបានវាស់វែងដោយជឿទុកចិត្ត។**

២០. ជាទូទៅ ការទទួលស្គាល់ចំណូលដោយយោងទៅលើដំណាក់កាលនៃការបញ្ចប់ប្រតិបត្តិការ គឺសំដៅដល់វិធីសាស្ត្របញ្ចប់ការងារតាមភាគរយ។ តាមវិធីសាស្ត្រនេះ ចំណូលត្រូវបានទទួលស្គាល់នៅក្នុងការិយបរិច្ឆេទរាយការណ៍ដែលសេវាត្រូវបានផ្តល់។ ឧទាហរណ៍ ស្ថាប័នមួយដែលផ្តល់សេវាវាយតម្លៃអចលនទ្រព្យ ត្រូវទទួលស្គាល់ចំណូល នៅពេលការវាយតម្លៃនីមួយៗត្រូវបានបញ្ចប់។ ការទទួលស្គាល់ចំណូលផ្អែកតាមមូលដ្ឋាននេះ ផ្តល់នូវព័ត៌មានដែលមានសារៈសំខាន់អំពីវិសាលភាពនៃសកម្មភាពផ្តល់សេវា និងលទ្ធផលការងារក្នុងអំឡុងការិយបរិច្ឆេទមួយ។ ស្តង់ដា CPSAS 11 ក៏តម្រូវឱ្យមានការទទួលស្គាល់ចំណូលតាមមូលដ្ឋាននេះផងដែរ។ ជាទូទៅ លក្ខខណ្ឌចាំបាច់នៃស្តង់ដានោះ អនុវត្តចំពោះការទទួលស្គាល់ចំណូលនិងចំណាយពាក់ព័ន្ធផ្សេងទៀតសម្រាប់ប្រតិបត្តិការមួយដែលពាក់ព័ន្ធនឹងការផ្តល់សេវា។

២១. ចំណូលត្រូវបានទទួលស្គាល់តែនៅពេលវាអាចនឹងកើតមានឡើងដែលអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវាដែលជាប់ពាក់ព័ន្ធនឹងប្រតិបត្តិការ នឹងហូរចូលស្ថាប័ន។ ទោះបីជាយ៉ាងណា នៅពេលដែលមានភាពមិន-ច្បាស់លាស់មួយកើតឡើងចំពោះភាពដែលអាចប្រមូលបាននៃចំនួនទឹកប្រាក់ដែលបានរួមបញ្ចូលរួចនៅក្នុងចំណូល នោះចំនួនទឹកប្រាក់ដែលមិនអាចប្រមូលបាន ឬ ចំនួនទឹកប្រាក់ដែលការប្រមូលត្រលប់មកវិញ មិនអាចនឹងកើតមានឡើង ត្រូវបានទទួលស្គាល់ជាចំណាយ ជាជាងជាការកែតម្រូវចំនួនទឹកប្រាក់នៃចំណូលដែលបានទទួលស្គាល់ពីដំបូង។

២២. ជាទូទៅ ស្ថាប័នអាចធ្វើការប៉ាន់ស្មានដោយជឿទុកចិត្ត បន្ទាប់ពីស្ថាប័នបានយល់ព្រមជាមួយភាគីផ្សេងទៀត ចំពោះប្រតិបត្តិការ នូវចំណុចដូចខាងក្រោម÷

(ក) សិទ្ធិស្របច្បាប់របស់ភាគីនីមួយៗ ពាក់ព័ន្ធនឹងសេវាដែលត្រូវផ្តល់ និងត្រូវទទួលដោយភាគី។

(ខ) តម្លៃតបស្នងដែលនឹងត្រូវធ្វើការដោះដូរ និង

(គ) មធ្យោបាយ និងលក្ខខណ្ឌនៃការទូទាត់។

ជាធម្មតា, ស្ថាប័នចាំបាច់ត្រូវមានប្រព័ន្ធថវិកាហិរញ្ញវត្ថុនិងប្រព័ន្ធរាយការណ៍ផ្ទៃក្នុងមួយដែលមានប្រសិទ្ធភាព។ ស្ថាប័នត្រូវពិនិត្យឡើងវិញ និងក្នុងករណីចាំបាច់ កែតម្រូវការប៉ាន់ស្មានចំណូលនៅពេលសេវាត្រូវបានបំពេញ។ សេចក្តីត្រូវការក្នុងការពិនិត្យឡើងវិញនេះ មិនបានបញ្ជាក់ថា លទ្ធផលនៃប្រតិបត្តិការ មិនអាចត្រូវបានប៉ាន់ស្មានដោយជឿទុកចិត្តនោះទេ។

២៣. ដំណាក់កាលនៃការបញ្ចប់ប្រតិបត្តិការ អាចត្រូវបានកំណត់ដោយវិធីសាស្ត្រច្រើន។ ស្ថាប័នប្រើប្រាស់វិធីសាស្ត្រដែលវាស់វែងដោយជឿទុកចិត្តនូវសេវាដែលត្រូវបានបំពេញ។ ដោយផ្អែកលើចរិតលក្ខណៈនៃប្រតិបត្តិការ, វិធីសាស្ត្រទាំងនោះអាចរួមមាន ដូចខាងក្រោម÷

(ក) ការស្ទង់មតិលើការងារដែលបានបំពេញ

(ខ) សេវាដែលបានបំពេញរហូតមកដល់ពេលបច្ចុប្បន្ន គិតជាភាគរយនៃសេវាសរុបដែលត្រូវបំពេញ ឬ

(គ) សមាមាត្រដែលចំណាយបានកើតឡើងរហូតមកដល់ពេលបច្ចុប្បន្ន ធៀបនឹងចំណាយប៉ាន់ស្មានសរុបនៃប្រតិបត្តិការ។ មានតែចំណាយដែលឆ្លុះបញ្ចាំងពីសេវាដែលបានបំពេញរហូតមកដល់ពេលបច្ចុប្បន្នប៉ុណ្ណោះដែលត្រូវបានបូកបញ្ចូលក្នុងចំណាយដែលបានកើតឡើងរហូតមកដល់ពេលបច្ចុប្បន្ន។ មានតែចំណាយដែលឆ្លុះបញ្ចាំងពីសេវាដែលបានបំពេញ ឬ នឹងត្រូវបំពេញប៉ុណ្ណោះដែលត្រូវបូកបញ្ចូលក្នុងចំណាយប៉ាន់ស្មានសរុបនៃប្រតិបត្តិការ។

ការទូទាត់ជាបន្តបន្ទាប់ និងបុរេប្រទានដែលបានទទួលពីអតិថិជន ជាទូទៅ មិនឆ្លុះបញ្ចាំងពីសេវាដែលបានបំពេញនោះទេ។

២៤. សម្រាប់គោលបំណងអនុវត្តជាក់ស្តែង នៅពេលសេវាត្រូវបានបំពេញដោយចំនួនសកម្មភាពដែលមិនអាចកំណត់បាននៅក្នុងរយៈពេលជាក់លាក់មួយ, ចំណូលត្រូវទទួលស្គាល់តាមមូលដ្ឋានរំលស់ថេរក្នុងរយៈពេលជាក់លាក់នោះ លើកលែងតែមានភស្តុតាងបង្ហាញថា វិធីសាស្ត្រដទៃផ្សេងទៀតបង្ហាញអំពីដំណាក់កាលនៃការបញ្ចប់ប្រតិបត្តិការបានល្អប្រសើរជាងនេះ។ នៅពេលសកម្មភាពជាក់លាក់មួយមានសារៈសំខាន់ច្រើនជាងសកម្មភាពផ្សេងទៀត, ការទទួលស្គាល់ចំណូលត្រូវបានពន្យារ រហូតដល់សកម្មភាពសំខាន់ត្រូវបានអនុវត្ត។

២៥. **នៅពេលលទ្ធផលនៃប្រតិបត្តិការដែលពាក់ព័ន្ធនឹងការផ្តល់សេវា មិនអាចប៉ាន់ស្មានបានដោយជឿទុកចិត្ត, ចំណូលត្រូវទទួលស្គាល់តែតាមទំហំចំណាយដែលបានទទួលស្គាល់រួចហើយអាចទទួលបានមកវិញប៉ុណ្ណោះ។**

២៦. នៅក្នុងអំឡុងពេលនៃដំណាក់កាលដំបូងនៃប្រតិបត្តិការ ជាធម្មតា លទ្ធផលនៃប្រតិបត្តិការមិនអាចប៉ាន់ស្មានបានដោយជឿទុកចិត្តនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ វាអាចនឹងកើតមានឡើងដែលស្ថាប័ននឹងទទួលបានមកវិញនូវចំណាយប្រតិបត្តិការដែលបានកើតឡើង។ ដូចនេះ ចំណូលត្រូវបានទទួលស្គាល់តែតាមទំហំចំណាយដែលបានកើតឡើង ហើយរំពឹងថានឹងអាចទទួលបានមកវិញប៉ុណ្ណោះ។ នៅពេលដែលលទ្ធផលនៃប្រតិបត្តិការមិនអាចត្រូវបានប៉ាន់ស្មានដោយជឿទុកចិត្ត អតិរេកមិនត្រូវបានទទួលស្គាល់នោះទេ។

២៧. នៅពេលដែល (ក) លទ្ធផលនៃប្រតិបត្តិការ មិនអាចត្រូវបានប៉ាន់ស្មានដោយជឿទុកចិត្ត ហើយ (ខ) ស្ថាប័នទំនងជានឹងមិនអាចទទួលបានមកវិញនូវថ្លៃដើមដែលបានកើតឡើង ចំណូលមិនត្រូវបានទទួលស្គាល់នោះទេ ហើយថ្លៃដើមដែលបានកើតឡើង ត្រូវទទួលស្គាល់ជាចំណាយ។ នៅពេលដែលភាពមិនច្បាស់លាស់រារាំងដល់លទ្ធផលនៃកិច្ចសន្យាដែលកំពុងត្រូវបានប៉ាន់ស្មានដោយជឿទុកចិត្ត លែងមានតទៅទៀត, ចំណូលត្រូវបានទទួលស្គាល់ដោយអនុលោមតាមកថាខណ្ឌ ១៩ ជាជាងដោយអនុលោមតាមកថាខណ្ឌ ២៥។

## ការលក់ទំនិញ

**២៨. ចំណូលពីការលក់ទំនិញត្រូវទទួលស្គាល់ នៅពេលដែលលក្ខខណ្ឌទាំងអស់ដូចខាងក្រោម ត្រូវបានបំពេញ÷**

**(ក) ស្ថាប័នបានផ្ទេរទៅឱ្យអ្នកទិញនូវហានិភ័យ និងផលប្រយោជន៍សំខាន់ៗនៃភាពជាម្ចាស់កម្មសិទ្ធិនៃទំនិញ**

**(ខ) ស្ថាប័នមិនរក្សានូវការជាប់ពាក់ព័ន្ធលើការគ្រប់គ្រងបន្តក្នុងកម្រិតណាមួយដែលជាប់ពាក់ព័ន្ធនឹងភាពជាម្ចាស់កម្មសិទ្ធិ និងមិនគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពលើទំនិញដែលបានលក់**

**(គ) ចំនួនទឹកប្រាក់នៃចំណូល អាចត្រូវបានវាស់វែងដោយជឿទុកចិត្ត**

**(ឃ) វាអាចនឹងកើតមានឡើងដែលអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវាដែលជាប់ពាក់ព័ន្ធនឹងប្រតិបត្តិការ នឹងហូរចូលស្ថាប័ន និង**

**(ង) ថ្លៃដើមដែលបានកើតឡើង ឬ នឹងត្រូវកើតឡើងពាក់ព័ន្ធនឹងប្រតិបត្តិការ អាចត្រូវបានវាស់វែងដោយជឿទុកចិត្ត។**

២៩. ការវាយតម្លៃអំពីពេលវេលាដែលស្ថាប័នមួយបានផ្ទេរហានិភ័យ និងផលប្រយោជន៍សំខាន់ៗនៃភាពជាម្ចាស់កម្មសិទ្ធិទៅឱ្យអ្នកទិញ គឺតម្រូវឱ្យមានការត្រួតពិនិត្យទៅលើកាលៈទេសៈនៃប្រតិបត្តិការ។ ក្នុងករណីភាគច្រើន ការផ្ទេរហានិភ័យនិងផលប្រយោជន៍នៃភាពជាម្ចាស់កម្មសិទ្ធិ កើតឡើងព្រមគ្នាជាមួយនឹងការផ្ទេរភាពជាម្ចាស់កម្មសិទ្ធិស្របច្បាប់ ឬ ការផ្ទេរការកាន់កាប់ទៅឱ្យអ្នកទិញ។ នេះគឺជាករណីសម្រាប់ការលក់ភាគច្រើន។ ទោះបីជាយ៉ាងនេះក្តី ក្នុងករណីជាក់លាក់ផ្សេងទៀត ការផ្ទេរហានិភ័យនិងផលប្រយោជន៍នៃភាពជាម្ចាស់កម្មសិទ្ធិ កើតឡើងនៅពេលវេលាខុសគ្នាពីការផ្ទេរភាពជាម្ចាស់កម្មសិទ្ធិស្របច្បាប់ ឬ ការផ្ទេរការកាន់កាប់។

៣០. ប្រសិនបើស្ថាប័ននៅរក្សាហានិភ័យសំខាន់ៗនៃភាពជាម្ចាស់កម្មសិទ្ធិ ប្រតិបត្តិការមិនមែនជាការលក់នោះទេ ហើយចំណូលក៏មិនត្រូវបានទទួលស្គាល់ផងដែរ។ ស្ថាប័នអាចរក្សាហានិភ័យសំខាន់ៗនៃភាពជាម្ចាស់កម្មសិទ្ធិ

តាមវិធីសាស្ត្រជាច្រើន។ ឧទាហរណ៍នៃស្ថានភាពដែលស្ថាប័នអាចរក្សាហានិភ័យនិងផលប្រយោជន៍សំខាន់ៗនៃភាពជាម្ចាស់កម្មសិទ្ធិ មានដូចខាងក្រោម÷

(ក) នៅពេលដែលស្ថាប័នរក្សាកាតព្វកិច្ច សម្រាប់លទ្ធផលមិនគាប់ប្រសើរដែលមិនត្រូវបានគ្របដណ្តប់ដោយការផ្តល់ការធានាធម្មតា

(ខ) នៅពេលដែលការទទួលបានចំណូលពីការលក់ជាក់លាក់ គឺអាស្រ័យលើការទាញយកចំណូលដោយអ្នកទិញពីការលក់ទំនិញរបស់ខ្លួន(ឧទាហរណ៍ នៅពេលរាជរដ្ឋាភិបាលដែលបោះផ្សាយកិច្ចប្រតិបត្តិការចែកចាយសម្ភារៈសិក្សាដល់សាលារៀន ដោយការលក់ ឬ បង្វិលមកឱ្យរាជរដ្ឋាភិបាលវិញ)

(គ) នៅពេលដែលទំនិញត្រូវបានដឹកជញ្ជូនដែលជាកម្មវត្ថុនៃការតំឡើង ហើយការតំឡើងគឺជាផ្នែកដ៏សំខាន់មួយនៃកិច្ចសន្យាដែលមិនទាន់ត្រូវបានបញ្ចប់ដោយស្ថាប័ននៅឡើយ និង

(ឃ) នៅពេលដែលអ្នកទិញមានសិទ្ធិទុកការទិញជាមោឃៈ ក្នុងហេតុផលដូចបានចែងក្នុងកិច្ចសន្យាលក់ ហើយស្ថាប័នមានភាពមិនច្បាស់លាស់អំពីភាពអាចកើតមានឡើងនៃការបង្វិលទំនិញត្រលប់មកវិញ។

៣១. ប្រសិនបើស្ថាប័ននៅរក្សាតែហានិភ័យនៃភាពជាម្ចាស់កម្មសិទ្ធិដែលមិនសំខាន់ នោះប្រតិបត្តិការគឺជាការលក់ ហើយចំណូលត្រូវបានទទួលស្គាល់។ ឧទាហរណ៍ អ្នកលក់អាចរក្សានូវកម្មសិទ្ធិស្របច្បាប់ចំពោះទំនិញ ដើម្បីតែបង្ការភាពអាចប្រមូលបាននៃចំនួនទឹកប្រាក់ដែលអ្នកទិញជំពាក់។ ក្នុងករណីនេះ ប្រសិនបើស្ថាប័នបានផ្ទេរហានិភ័យនិងផលប្រយោជន៍សំខាន់ៗនៃភាពជាម្ចាស់កម្មសិទ្ធិ ប្រតិបត្តិការគឺជាការលក់ ហើយចំណូលត្រូវបានទទួលស្គាល់។ ឧទាហរណ៍មួយទៀតនៃស្ថាប័នដែលនៅរក្សាហានិភ័យនៃភាពជាម្ចាស់កម្មសិទ្ធិដែលមិនសំខាន់អាចជាការលក់ នៅពេលស្ថាប័នយល់ព្រមបង្វិលសងប្រាក់ទៅឱ្យអ្នកទិញវិញ ប្រសិនបើអ្នកទិញមិនពេញចិត្ត។ ក្នុងករណីនេះ ចំណូលត្រូវបានទទួលស្គាល់នៅពេលលក់ នៅពេលដែលអ្នកលក់អាចប៉ាន់ស្មានការបង្វិលសងនាពេលអនាគតដោយជឿទុកចិត្ត និងទទួលស្គាល់ជាបំណុលសម្រាប់ការបង្វិលសង ដោយផ្អែកលើបទពិសោធន៍ពីអតីតកាល និងកត្តាពាក់ព័ន្ធផ្សេងទៀត។

៣២. ចំណូលត្រូវបានទទួលស្គាល់ តែនៅពេលវាអាចនឹងកើតមានឡើងដែលអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវាដែលជាប់ពាក់ព័ន្ធនឹងប្រតិបត្តិការ នឹងហូរចូលស្ថាប័នប៉ុណ្ណោះ។ ក្នុងករណីមួយចំនួន ស្ថានភាពនេះអាចនឹងមិនកើតឡើង រហូតដល់តម្លៃតបស្នងត្រូវបានទទួល ឬ រហូតដល់ភាពមិនច្បាស់លាស់ត្រូវបានដកចេញ។ ឧទាហរណ៍ ចំណូលអាចពឹងផ្អែកលើសមត្ថភាពរបស់ស្ថាប័នដទៃក្នុងការផ្គត់ផ្គង់ទំនិញជាផ្នែកមួយនៃកិច្ចសន្យា ហើយប្រសិនបើមានការសង្ស័យថាករណីនេះនឹងកើតឡើង ការទទួលស្គាល់ចំណូលអាចត្រូវបានពន្យារពេលរហូតដល់ប្រតិបត្តិការបានកើតឡើងជាក់ស្តែង។ នៅពេលទំនិញត្រូវបានផ្គត់ផ្គង់ ភាពមិនច្បាស់លាស់ត្រូវបានដកចេញ ហើយចំណូលត្រូវបានទទួលស្គាល់។ ទោះបីជាយ៉ាងនេះក្តី នៅពេលភាពមិនច្បាស់លាស់កើតឡើងពាក់ព័ន្ធនឹងភាពអាចប្រមូលបាននៃចំនួនទឹកប្រាក់ដែលបានបូកបញ្ចូលរួចនៅក្នុងចំណូល នោះទឹកប្រាក់ដែលមិនអាចប្រមូលបាន ឬ ចំនួនទឹកប្រាក់ដែលការប្រមូលត្រលប់មកវិញមិនអាចនឹងកើតមានឡើង ត្រូវបានទទួលស្គាល់ជាចំណាយ ជាជាងជាការកែតម្រូវចំនួនទឹកប្រាក់នៃចំណូលដែលបានទទួលស្គាល់ពីដំបូង។

## ការប្រាក់ សួយសារ និងភាគលាភ ឬ ការបែងចែកប្រហាក់ប្រហែល

៣៣. ចំណូលដែលកើតឡើងពីការប្រើប្រាស់ទ្រព្យសកម្មដោយស្ថាប័នដទៃ ដែលផ្តល់ជាការប្រាក់ សួយសារ និងភាគលាភ ឬ ការបែងចែកប្រហាក់ប្រហែល ត្រូវបានទទួលស្គាល់ ដោយប្រើប្រព្រឹត្តិកម្មគណនេយ្យដូចបានកំណត់ក្នុងកថាខណ្ឌ ៣៤ នៅពេល÷

(ក) វាអាចនឹងកើតមានឡើងដែលអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវាដែលជាប់ពាក់ព័ន្ធនឹងប្រតិបត្តិការ នឹងហូរចូលស្ថាប័ន និង

(ខ) ចំនួនទឹកប្រាក់នៃចំណូល អាចត្រូវបានវាស់វែងដោយជឿទុកចិត្ត។

៣៤. ចំណូលត្រូវបានទទួលស្គាល់ដោយប្រើប្រព្រឹត្តិកម្មគណនេយ្យ ដូចខាងក្រោម÷

(ក) ការប្រាក់ត្រូវបានទទួលស្គាល់តាមមូលដ្ឋានសមាមាត្រពេលវេលា ដោយគិតពីទិន្នផលប្រសិទ្ធភាពលើទ្រព្យសកម្ម

(ខ) សួយសារត្រូវបានទទួលស្គាល់ នៅពេលសួយសារទាំងនោះត្រូវបានទទួល ដោយអនុលោមតាមខ្លឹមសារនៃកិច្ចព្រមព្រៀងពាក់ព័ន្ធ និង

(គ) ភាគលាភ ឬ ការបែងចែកប្រហាក់ប្រហែល ត្រូវបានទទួលស្គាល់ នៅពេលសិទ្ធិរបស់ម្ចាស់ភាគហ៊ុន ឬ សិទ្ធិរបស់ស្ថាប័នដើម្បីទទួលបានការទូទាត់ ត្រូវបានបង្កើតឡើង។

៣៥. ទិន្នផលប្រសិទ្ធភាពលើទ្រព្យសកម្ម គឺជាអត្រាការប្រាក់ដែលត្រូវបានតម្រូវ ដើម្បីធ្វើអប្បហារលើលំហូរនៃចំណូលសាច់ប្រាក់នាពេលអនាគតដែលបានរំពឹងទុកពេញមួយអាយុកាលនៃទ្រព្យសកម្ម ដើម្បីឱ្យស្មើទៅនឹងតម្លៃយោងដំបូងនៃទ្រព្យសកម្មនោះ។ ចំណូលពីការប្រាក់ រួមមាន ចំនួនទឹកប្រាក់រំលស់នៃការធ្វើអប្បហារ បុព្វលាភ ឬ ភាពខុសគ្នាផ្សេងទៀតណាមួយ រវាងតម្លៃយោងដំបូងនៃមូលបត្របំណុល និងចំនួនទឹកប្រាក់នៃមូលបត្របំណុលនោះ នាកាលវសាន។

៣៦. នៅពេលការប្រាក់ដែលមិនទាន់ទូទាត់ត្រូវបានបង្គរទុក មុនពេលការទទួលបាននូវការវិនិយោគដែលបង្កើតការប្រាក់, ការប្រាក់ដែលបានទទួលជាបន្តបន្ទាប់ ត្រូវបានបែងចែករវាងការិយបរិច្ឆេទមុនពេលទិញនិងការិយ-បរិច្ឆេទក្រោយពេលទិញ; មានតែចំណែកនៃការប្រាក់ក្រោយពេលទិញប៉ុណ្ណោះដែលត្រូវបានទទួលស្គាល់ជាចំណូល។ នៅពេលភាគលាភ ឬ ការបែងចែកប្រហាក់ប្រហែលលើមូលបត្រកម្មសិទ្ធិត្រូវបានប្រកាសពីអតិរេកសុទ្ធមុនពេលទិញ, ភាគលាភ ឬ ការបែងចែកប្រហាក់ប្រហែលទាំងនោះត្រូវបានដកចេញពីថ្លៃដើមមូលបត្រ។ ប្រសិនបើមានការពិបាកក្នុងការបែងចែក លើកលែងតាមតែការសម្រេចចិត្ត, នោះភាគលាភ ឬ ការបែងចែកប្រហាក់ប្រហែល ត្រូវបានទទួលស្គាល់ជាចំណូល លុះត្រាតែភាគលាភ ឬ ការបែងចែកប្រហាក់ប្រហែល បានបង្ហាញយ៉ាងច្បាស់អំពីការទទួលបានមកវិញនូវថ្លៃដើមមូលបត្រកម្មសិទ្ធិនោះ។

៣៧. សួយសារ ដូចជា សួយសារបានពីប្រេងឥន្ធនៈ ដែលបានបង្គរដោយអនុលោមតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងដែលពាក់ព័ន្ធ ហើយជាទូទៅត្រូវបានទទួលស្គាល់ដោយផ្អែកលើមូលដ្ឋាននៃកិច្ចព្រមព្រៀងនោះ លើកលែងតែមានចែងជាក់លាក់ក្នុងកិច្ចព្រមព្រៀង ស្ថាប័នអាចទទួលស្គាល់ជាចំណូល ដោយផ្អែកលើមូលដ្ឋានជាលក្ខណៈប្រព័ន្ធ និងមូលដ្ឋានសមហេតុផលផ្សេងទៀត។

៣៨. ចំណូលត្រូវបានទទួលស្គាល់ តែនៅពេលវាអាចនឹងកើតមានឡើងដែលអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវាដែលជាប់ពាក់ព័ន្ធនឹងប្រតិបត្តិការ នឹងហូរចូលស្ថាប័ន។ ទោះបីជាយ៉ាងនេះ នៅពេលភាពមិនច្បាស់លាស់កើតឡើងពាក់ព័ន្ធនឹងភាពអាចប្រមូលបាននៃចំនួនទឹកប្រាក់ដែលបានបូកបញ្ចូលរួចក្នុងចំណូល នោះទឹកប្រាក់ដែលមិនអាចប្រមូលបាន ឬ ចំនួនទឹកប្រាក់ដែលការប្រមូលត្រលប់មកវិញ មិនអាចនឹងកើតមានឡើង ត្រូវបានទទួលស្គាល់ជាចំណាយ ជាជាងជាការកែតម្រូវចំនួនទឹកប្រាក់នៃចំណូលដែលបានទទួលស្គាល់ពីដំបូង។

## ការលាតត្រដាង

៣៩. **ស្ថាប័នត្រូវលាតត្រដាង÷**

(ក) **គោលនយោបាយគណនេយ្យដែលបានប្រើសម្រាប់ការទទួលស្គាល់ចំណូល រួមបញ្ចូលទាំងវិធីសាស្ត្រដែលបានប្រើដើម្បីកំណត់អំពីដំណាក់កាលនៃការបញ្ចប់ប្រតិបត្តិការពាក់ព័ន្ធនឹងការផ្តល់សេវា**

(ខ) **ចំនួនទឹកប្រាក់នៃខ្ទង់ចំណូលសំខាន់ៗនីមួយៗដែលបានទទួលស្គាល់នៅក្នុងអំឡុងការិយបរិច្ឆេទ រួមបញ្ចូលទាំងចំណូលដែលបានមកពី÷**

១) **ការផ្តល់សេវា**

២) **ការលក់ទំនិញ**

៣) **ការប្រាក់**

៤) **សួយសារ និង**

៥) **ភាគលាភ ឬ ការបែងចែកប្រហាក់ប្រហែល និង**

(គ) **ចំនួនទឹកប្រាក់នៃចំណូលដែលបានមកពីការដោះដូរទំនិញ ឬ សេវាដែលបានរួមបញ្ចូលនៅក្នុងខ្ទង់ចំណូលសំខាន់ៗនីមួយៗ។**

៤០. ការណែនាំស្តីពីការលាតត្រដាងអំពីទ្រព្យសកម្មយថាហេតុ និងបំណុលយថាហេតុណាមួយ អាចមើលបានក្នុងស្តង់ដា CPSAS 19 សំវិធានធន បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ។ ទ្រព្យសកម្មយថាហេតុ និងបំណុលយថាហេតុ អាចកើតឡើងពីធាតុដូចជា ចំណាយការធានា, ការទាមទារ, ការផ្តន្ទាទោសពិន័យជាប្រាក់ ឬ ការខាតបង់ដែលអាចកើតមាន។

## CPSAS 9 – REVENUE FROM EXCHANGE TRANSACTIONS

**Acknowledgment**

